**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ 0265 .....អបស/ក្រអបស

រាជធានីភ្នំពេញ, ថ្ងៃទី 09 ខែ 06 ឆ្នាំ២០០9

# សេចក្ដីណែនាំ

## ស្ដីពី

## ការអនុវត្តន៍ភារកិច្ចរបស់គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ ដើម្បីកាត់បន្ថយភាពក្រីក្រ

ដោយពិនិត្យឃើញថា ការលុបបំបាត់ឱសថក្លែងក្លាយនិងសេវាសុខាភិបាលខុសច្បាប់ ទាមទារការចូលរួមយ៉ាងសកម្ម និងសហការយ៉ាងជិតស្និទ្ធពីក្រសួងពាក់ព័ន្ធនិងអាជ្ញាធរដែនដី ជាក់ស្ដែងក្នុងរយៈពេលជាង២០ឆ្នាំកន្លងមកនេះ ទោះបីជាក្រសួងសុខាភិបាលបានខិតខំយ៉ាងណា ក៏ភាពអសកម្មនៅតែកើតមានជាដដែល ហេតុនេះហើយបានជារាជរដ្ឋាភិបាលបានសម្រេចចេញសេចក្ដីសម្រេចលេខ ៣៣ សសរ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៥ ស្ដីពីការ បង្កើតគណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ ដើម្បីកាត់បន្ថយភាពក្រីក្រសំរាប់ជាមូលដ្ឋានក្នុងការអនុវត្តន៍ ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពការងារឱ្យទទួលបាននូវលទ្ធផលល្អ ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាល ប្រធានគណៈកម្មការអន្តរក្រសួងសូមធ្វើការណែនាំនូវភារកិច្ចលំអិតដូចខាងក្រោម :

១-<u>ក្រសួងសុខាភិបាលត្រូវមានភារកិច្ច</u> :

- រៀបចំលិខិតបទដ្ឋានផ្សេងៗដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្ដីសម្រេច សារាចរណែនាំ សេចក្ដីជូនដំណឹង ។ល។ ដែលពាក់ព័ន្ធនឹងសកម្មភាពលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- រៀបចំប្រជុំផ្សព្វផ្សាយ និងណែនាំការអនុវត្តន៍លិខិតបទដ្ឋានផ្សេងៗ ដល់គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលនាំចេញ និងចែកចាយឱសថ គ្រឹះស្ថានលក់ដុំ លក់រាយឱសថ និងកន្លែងលក់ឱសថគ្មានច្បាប់អនុញ្ញាត សំដៅលើកកម្ពស់ការគោរពច្បាប់ និងធានានូវឱសថ មានគុណភាព ប្រសិទ្ធភាព និង សុវត្ថិភាព
- រៀបចំប្រជុំផ្សព្វផ្សាយ និងណែនាំក្នុងការអនុវត្តន៍លិខិតបទដ្ឋានផ្សេងៗ ដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ និងសេវាសុខាភិបាលគ្មានច្បាប់អនុញ្ញាតសំដៅលើកកម្ពស់ការគោរពច្បាប់ និងមនសិការវិជ្ជាជីវៈ
- រៀបចំសេចក្ដីប្រកាសព័ត៌មាន ប័ណ្ណរូបភាពឱសថក្លែងក្លាយ សៀវភៅរូបភាពឱសថក្លែងក្លាយ ឱសថហាមឃាត់ ឱសថដែលលុបចេញពីទិដ្ឋាការ-បញ្ជិកាឱសថ ដើម្បីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីគ្រោះថ្នាក់ នៃការប្រើប្រាស់ឱសថក្លែងក្លាយ
- ផ្សព្វផ្សាយ អប់រំ លើកកម្ពស់ដល់សាធារណជនអំពីគ្រោះថ្នាក់ នៃការប្រើសេវាសុខាភិបាលឯកជនខុសច្បាប់
- ពង្រឹងការគ្រប់គ្រង ការនាំចូលឱសថ ផលិតកម្មឱសថ និងប្រព័ន្ធចុះទិដ្ឋាការ-បញ្ជិកាឱសថ



ទីស្ដីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

- លើកកម្ពស់សមត្ថភាពបច្ចេកទេសត្រួតពិនិត្យគុណភាពឱសថ របស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយបង្កើតបណ្តាញផ្លាស់ប្តូរព័ត៌មានឱសថជាមួយអាជ្ញាធរឱសថ ចំណីអាហារ ប្រទេសនានា អង្គការសុខភាពពិភពលោក និងអង្គការនានា ដើម្បីស្រាវជ្រាវរកប្រភពឱសថក្លែងក្លាយ
- ពង្រឹងការទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក រវាងប្រទេសនានា ក្នុងការបើកចំហទូលាយឱ្យមកប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

២-ក្រសួងសុខាភិបាលត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរាជធានីភ្នំពេញ ដើម្បី :

- បង្ក្រាបកន្លែងផលិតឱសថ និង ឃ្លាំងស្តុកឱសថដែលគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ព្រមទាំងមានវិធានការលុបបំបាត់
- ឃាត់ទុកនូវឱសថក្លែងក្លាយ ឱសថនាំចូលខុសច្បាប់ដែលគ្មានលិខិតអនុញ្ញាតនាំចូលពីក្រសួងសុខាភិបាល និងមានវិធានការតាមផ្លូវច្បាប់
- បង្ក្រាបសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ និង សេវាសុខាភិបាលផ្សេងៗទៀត ដែលគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ព្រមទាំងមានវិធានការលុបបំបាត់ ។

៣-ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងយុត្តិធម៌ ដោយមានយន្តការ ការងារដូចខាងក្រោម :

- គណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់រាជធានី និងខេត្ត មានសិទ្ធិដោះស្រាយរាល់ករណីបទល្មើសទាំងឡាយទៅតាមនីតិវិធីតុលាការ
- គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ នឹងត្រៀមជួយដោះស្រាយក្នុងរាល់ករណីដែលគណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់រាជធានី និងខេត្តមិនមានលទ្ធភាពដោះស្រាយ ។

៤-ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី :

- ទប់ស្កាត់ការនាំចូលឱសថខុសច្បាប់ តាមបណ្តាច្រកទ្វារអន្តរជាតិ ច្រករបៀង និងច្រកផ្សេងៗទៀត ។

៥-ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បី :

- ទប់ស្កាត់ការនាំចូល ការនាំចេញ ការដឹកជញ្ជូនវត្ថុធាតុធម្មជាតិខុសច្បាប់ដូចជារុក្ខជាតិឱសថ សត្វ សិលាជាតិ សំរាប់ផលិតឱសថបុរាណ ។

៦-ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងព័ត៌មាន ដើម្បី :

- ផ្សព្វផ្សាយតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយនូវប្រកាសព័ត៌មានឱសថក្លែងក្លាយ បញ្ជីរូបភាពឱសថក្លែងក្លាយ ឱសថហាមឃាត់ ឱសថដែលលុបចេញពីបញ្ជីចុះលេខទិដ្ឋាការ-បញ្ជិកាឱសថ ដើម្បីអប់រំលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីគ្រោះថ្នាក់នៃការប្រើប្រាស់ឱសថក្លែងក្លាយ

- ផ្សព្វផ្សាយ អប់រំ លើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីគ្រោះថ្នាក់នៃការប្រើសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ និងសេវាសុខាភិបាលឯកជនខុសច្បាប់
- ហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថ-ការផ្សព្វផ្សាយពាណិជ្ជកម្មសេវាសុខាភិបាលផ្សេងៗទៀត ដែលគ្មានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

៧-ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បី :

- សម្រួលកម្មវិធី ទីតាំង និងពេលវេលា ដើម្បីចុះផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់សិស្ស និស្សិតអំពីគ្រោះថ្នាក់នៃការប្រើប្រាស់ឱសថក្លែងក្លាយ
- សម្រួលឱ្យមានការបិទផ្ទាំងរូបភាព ព្រឹត្តិប័ត្រព័ត៌មានអំពីឱសថក្លែងក្លាយ តាមបណ្តាថ្នាក់រៀន តាមសាលារៀន។

៨-សមាជិកគណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ មានភារកិច្ច :

- ចូលរួមនិងធ្វើការសម្របសម្រួលជាមួយជំនាញនៃក្រសួងសាម៉ីក្នុងការសម្រេច គោលដៅលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

៩-គណៈកម្មការអន្តរក្រសួង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ :

- ត្រូវធ្វើការបូកសរុបសកម្មភាព និង លទ្ធផលដែលទទួលបានពីគណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយ និង សេវាសុខាភិបាលខុសច្បាប់រាជធានី និងខេត្ត ដើម្បីផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់ដំណាច់ឆ្នាំ ។

គណៈកម្មការអន្តរក្រសួង លុបបំបាត់

ឱសថក្លែងក្លាយ និង សេវាសុខាភិបាលខុសច្បាប់

ប្រធាន

ម៉ម_ប៊ុនហេង

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
  គណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់រាជធានី-ខេត្ត
- អគ្គនាយកបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- នាយកដ្ឋានមន្ទីរពេទ្យ
- មន្ទីរសុខាភិបាលខេត្ត-ក្រុង
- កាលប្បវត្តិ
- ឯកសារ